# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**អាជ្ញាធរជាតិ ប្រយុទ្ធនឹងជំងឺអេដស៍**
**នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ**

### កំណត់ហេតុ
### កិច្ចប្រជុំការងារបច្ចេកទេសប្រចាំសប្តាហ៍

**ថ្ងៃ ច័ន្ទ ទី២២ ខែ មិថុនា ឆ្នាំ ២០១៥ នៅសាលប្រជុំ អ.ជ.ប.ជ.អ**

នៅវេលាម៉ោង ៩:០០ នាទីព្រឹក ថ្ងៃច័ន្ទ ទី២២ ខែ មិថុនា ឆ្នាំ២០១៥ អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានរៀបចំកិច្ចប្រជុំការងារបច្ចេកទេសប្រចាំសប្តាហ៍ របស់ខ្លួនក្រោមការដឹកនាំ កិច្ចប្រជុំដោយឯកឧត្តមវេជ្ជបណ្ឌិត តែង គន្ធី អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការ ចូលរួមពីអគ្គលេខាធិការរង ប្រធាន និងអនុប្រធាននាយកដ្ឋានក្រោមឱវាទអគ្គលេខាធិការដ្ឋាន។

**១. សមាសភាពចូលរួម:**

សមាសភាពចូលរួមក្នុងកិច្ចប្រជុំថ្ងៃនេះ មានអគ្គលេខាធិការ អគ្គលេខាធិការរង ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន សរុបទាំងអស់ចំនួន ២០រូប (មានភ្ជាប់ជូនបញ្ជីវត្តមានចូលរួម)។

**២. អវត្តមាន** ( រូប )

លោកវេជ្ជ.អ៊ុក ម៉ារាឌី (បេសកកម្ម)

**៣. ប្រធានបទនៃកិច្ចប្រជុំ**

- របាយការណ៍សកម្មភាពសំរាប់សប្តាហ៍កន្លងមកនិងសកម្មភាពសំរាប់សប្តាហ៍បន្ទាប់របស់នាយកដ្ឋាននីមួយៗ
- សំណូមពររួម និងផ្សេងៗ

- ការណែនាំរបស់អគ្គលេខាធិការតាមនាយកដ្ឋាន

**៤. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ .**

ជាកិច្ចចាប់ផ្តើមនៃអង្គប្រជុំ ឯកឧត្តមវេជ្ជ. តែង គន្ធី អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានមតិស្វាគមន៍ចំពោះ ឯកឧត្តម លោក លោកស្រី អគ្គលេខាធិការរង ប្រធាន និងអនុប្រធាននាយកដ្ឋានទាំងអស់ដែលបានចូលរួមក្នុងកិច្ចប្រជុំនាព្រឹកនេះ ។

ជាបន្តឯកឧត្តមប្រធានអង្គប្រជុំ បានប្រគល់វេទិកាទៅនាយកដ្ឋាននីមួយៗដើម្បី ធ្វើរបាយការណ៍សកម្មភាព ដែលបានអនុវត្តនៅសប្តាហ៍កន្លងមក និង ផែនការសកកម្មភាពសំរាប់អនុវត្តសប្តាហ៍បន្ទាប់ទៀតដូចខាងក្រោម ៖

**៤ .១.នាយកដ្ឋាន បង្ការ ថែទាំ និង គាំទ្រ**

លោកវេជ្ជ .វ៉ុីង យ៉ាណាត ប្រធាននាយកដ្ឋាន បានរាយការណ៍ ជូនអង្គនូវសកម្មភាពការងារ ដែលបានអនុវត្តក្នុងសប្តាហ៍កន្លងមក និងសំរាប់សប្តាហ៍បន្ទាប់ រួមមាន៖

- ចូលរួមប្រជុំរៀបចំផែនការសកម្មភាពសម្រាប់គម្រោងមូលនិធិសកលជាមួយ ឯកឧត្តម ទា ផលា អនុប្រធាន អ.ជ.ប.ជ.អ។
- បញ្ជូនមន្ត្រីចូលរួមពិនិត្យស្ថានភាពមេរោគអេដស៍នៅខេត្តសៀមរាប បន្ទាយមានជ័យ និងបាត់ដំបង ដឹកនាំដោយ ឯកឧត្តម ទា ផល្លា អនុប្រធាន អ.ជ.ប.ជ.អ។
- ប្រជុំក្រុមការងារលេខាធិការដ្ឋានបុរសស្រឡាញ់បុរស និងស្រីស្រស់ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងគោលបំណងពិភាក្សារៀបចំរបៀបវារៈកិច្ចប្រជុំក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរសនិងស្រីស្រស់និងកែសំរួល បទបង្ហាញ នៅថ្ងៃទី ២៥ មិថុនា ២០១៥។

**៤.២.នាយកដ្ឋាន ទាក់ទង និង ចលនាប្រភពធនធាន**

លោកវេជ្ជ. ស៊ឹម គឹមសាន ប្រធាននាយកដ្ឋាន បានរាយការណ៍ ជូនអង្គប្រជុំនូវសកម្មភាពការងារ ដែលបានអនុវត្តក្នុងសប្តាហ៍កន្លងមក និងសំរាប់សប្តាហ៍បន្ទាប់ រួមមាន៖

- បានរៀបបញ្ជីឈ្មោះសមាជិក សមាជិកា ដែលត្រូវចូលរួមប្រជុំនៅថ្ងៃទី ៣០ មិថុនា ២០១៥ ឲ្យទៅនាយកដ្ឋានរដ្ឋបាល រួចហើយ
- GDJ លើកថ្ងៃប្រជុំ និងពិភាក្សាក្នុងនាយកដ្ឋានពេលក្រោយ

**៤.៣ នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និងស្រាវជ្រាវ**

លោកវេជ្ជ. រស់ សីលវ៉ាត់ អគ្គលេខាធិការរង និងជាប្រធាននាយកដ្ឋាន បានរាយការណ៍ជូនអង្គប្រជុំ នូវសកម្មភាពការងារ ដែលបានអនុវត្តក្នុងសប្តាហ៍កន្លងមក និងសំរាប់សប្តាហ៍បន្ទាប់ រួមមានៈ

- បានបញ្ចប់របាយការណ៍ GARPR និង ដាក់បញ្ចូលទៅ Online រួចរាល់
- NSP IV កំពុងកែសំរួលនិងបានផ្ញើទៅ Jame ហើយតែមិនទាន់ឃើញត្រឡប់មកវិញ
- ពិនិត្យមើល Log frame នៃ NSP IV និងរៀបចំបកប្រែ
- បានបញ្ចូលទិន្នន័យ បេសកកម្ម តែមិនទាន់បានបញ្ចប់
- រៀបចំទិន្នន័យដែលទទួលបាន និងចងក្រងបទបង្ហាញរបាយការណ៍ ៦ខែ ដើមឆ្នាំ តែនៅខ្វះទិន្នន័យពីដៃគូសហការណ៍ច្រើន ដែលយើងកំពុងព្យាយាមប្រមូលបន្ត
- ចុះបេសកកម្មពិនិត្យលើការងារដែលអនុវត្តនៅខេត្តកំពុងស្ពឺ និងត្រៀមចុះពិនិត្យការងារអនុវត្តនៅខេត្តបន្ទាយមានជ័យក្រោមជំនួយ CDC និងរៀបចំថត Video Clip សម្រាប់ផ្សព្វផ្សាយនៅថ្ងៃទី ២ ឆ្នូ ជាមួយ ឯឧ. ទា ផលា ។

ឯឧ. អគ្គលេខាធិការ បានណែនាំថាការបញ្ចូលទិន្នន័យបេសកម្មអាចឲ្យ **លោក កែវ ចំណាន** បាន មិនចាំបាច់លោកលី ចាន់វ៉ារុធ ហើយក្នុងនោះទិន្នន័យឯឧ. អគ្គលេខាធិការ ចង់ដឹងសំខាន់គឺថាតើក្នុង ៦ខេត្ត មានក្រុមប្រឈមប៉ុន្មាន។

៤.៣ នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ

ឯ.ឧ សឺន ពិសិដ្ឋ ប្រធាននាយកដ្ឋាន បានរាយការណ៍សកម្មភាពការងារដែលបាន អនុវត្តក្នុងសប្តាហ៍កន្លងមក រួមមាន:

- បានចុះស្រងបញ្ជីសារសារពើព័ណ្ឌក្នុងនាយកដ្ឋានPMERD
- ប្រជុំមន្ត្រីក្នុងនាយដ្ឋានក្រោមការដឹកនាំរបស់ ឯឧ.អគ្គលេខាធិការរង ឈឹម ឃឺនដារ៉េត ដើម្បីពិនិត្យមើលសកម្មភាពការងារស្នើសុំគោលការណ៍ដែលបានដាក់ទៅក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ (ប្រេង, ប្រជុំពេញអង្គ, សន្និបាត ប្រចាំឆ្នាំ, ជួសជុលរថយន្ត...)
- រៀបចំលើកគោលការណ៍សំរាប់ការប្រជុំយែនឌ័រ, និងបោះពុម្ពសៀវភៅផែនការយុទ្ធសាស្ត្រជាតិលើកទី៤
- កំពុងសិក្សាលើការសុំគោលការទៅប្រជុំ ICAAP នៅប្រទេសបង់ក្លាដេស

## ៥. សកម្មភាពក្នុងសប្តាហ៍បន្ទាប់ ៖

### ៥.១. នាយកដ្ឋាន ផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ៖

- បន្តពិនិត្យកែសម្រួលបន្ថែមលើសេចក្តីព្រៀង NSP IV ដែលទទួលបានពីទីប្រឹក្សាបច្ចេកទេស
- បន្តពិនិត្យបច្ចុប្បន្នភាព Update Situation
- បញ្ចប់ Log frame នៃ NSP IV ត្រៀមបកប្រែ និងរៀបចំជាបទបង្ហាញសំរាប់អង្គប្រជុំក្រុមប្រឹក្សាគោនយោបាយ ថ្ងៃទី៣០ មិថុនា ឆ្នាំ ២០១៥
- ចូលរួមរៀបចំផែនការលំអិតថវិកាជាតិឆ្នាំ ២០១៦
- រៀបចំបញ្ចប់របាយការណ៍ប្រចាំខែ
- រៀបចំការប្រជុំ លេខាធិការដ្ឋានក្រុមការងារ GDJ  នាចុងសប្តាហ៍នេះ

### ៥.២. សំណូមពររួម និងផ្សេងៗ៖

- ឯ.ឧ ស៊ិន ពិសិដ្ឋ ស្នើគ្រប់នាយកដ្ឋាន ចូលរួមធ្វើផែនការថវិកាឆ្នាំ ២០១៦ តម្រូវធ្វើឲ្យហើយនៅថ្ងៃទី ២៥ មិថុនា ជាកំហិត
- លោកវេជ្ជ. រស់ សីលវ៉ាត់ ស្នើសុំឲ្យមានការចាប់ផ្តើមស្នើថវិកាជាតិសំរាប់ធ្វើផែនការ៣ឆ្នាំរំកិល
- លោកវេជ្ជ. រស់ សីលវ៉ាត់ ស្នើសុំឲ្យគ្រប់នាយកដ្ឋានផ្ញើរបាយការណ៍ប្រចាំខែមិថុនា មកនាយកដ្ឋាន PMER ក្នុងថ្ងៃនេះ (ថ្ងៃទី២២ មិថុនា ឆ្នាំ ២០១៥)
- ឯឧ. ជា ប៉ោ សុំឲ្យមានទំនាក់ទំនងគ្នា រវាងមន្ត្រី និងប្រធាននាយកដ្ឋាន រាល់ការងារត្រូវធ្វើរបាយការណ៍ជូនប្រធាននាយកដ្ឋាន ។

### ៥.៣. ភារៈកិច្ចបន្តទូទៅសំរាប់សប្តាហ៍បន្ទាប់៖

- នាយកដ្ឋាន រដ្ឋបាល មានភារកិច្ចបញ្ចេញលិខិតអញ្ជើញសមាជិកចូលរួមប្រជុំ PAB
- ឯឧ. ឈឹម ឃិនដារ៉េត និងប្រធាននាយកដ្ឋាន រដ្ឋបាល និងហិរញ្ញវត្ថុទទួលប្រជុំការងារធ្វើផែនការឆ្នាំ ២០១៦ ។
- នាយកដ្ឋានPMER ត្រូវធ្វើការជាមួយ ឯឧ. ទា ផលា បញ្ហា log Frame
- ឯឧ. ជា ប៉ោ ទទួលរៀបចំការប្រជុំ TAB ថ្ងៃស្អែក ទី២៣ មិថុនា បើមានការលំបាកយ៉ាងណាស្នើសរសេរជាអក្សរស្នើទៅថ្នាក់ដឹកនាំដើម្បីពិនិត្យលើបញ្ហានេះពីព្រោះការប្រជុំនេះមានសារៈសំខាន់ណាស់ក្នុងការបង្ហាញពីអណត្តិការងាររបស់អង្គាធរ។

- មន្ត្រីដែលបានចាត់តាំងធ្វើការងារ តាមរយៈណាក៏ដោយប្រធាននាយកដ្ឋានត្រូវណែនាំឲ្យធ្វើ របាយការណ៍ជូនប្រធានយកដ្ឋានមួយច្បាប់។
- ឯឧ. អគ្គរងទទួលបន្ទុក និង លោកវ៉ឹង យ៉ាណាត ពិភាក្សាពីការងារ OVC តើសម្រេចយ៉ាងណា
- លោកអ៊ុក ម៉ារឌី ត្រូវធ្វើរបាយការណ៍ ពីផលប្រយោជន៍ក្នុងការចូលរួមការងារ OVC
- នាយកដ្ឋាន រដ្ឋបាល និងហិរញ្ញវត្ថុស្រង់បញ្ជីរសារពើព័ណ្ឌគ្រប់នាយកដ្ឋាន
- នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុត្រូវធ្វើរបាយការណ៍ Financial report 6 month ជូនឯឧ. អគ្គលេខាធិការ
- ប្រជុំថ្នាក់ដឹកនាំ ថ្ងៃទី ២៥ មិថុនា ២០១៥ វេលាម៉ោង ៨និង៣០នាទីព្រឹក
- កិច្ចប្រជុំរួមប្រចាំខែ នៅសប្តាហ៍ក្រោយ ត្រូវពិនិត្យមើលបញ្ជីវត្តមានឲ្យបានជាប្រចាំ
- ករណីកម្មវិធីប្រជុំ PAB
  - NSPIV គួរដូរឆ្នាំ ពី ២០១៥-២០២០ ទៅ ២០១៦-២០២០
  - CRM និងរដ្ឋបាលហិរញ្ញវត្ថុ ត្រូវរៀបចំចុះបញ្ជីវត្តមាន (ពន្យល់ពីរបៀប Protocol ទទួលភ្ញៀវជាតិ អន្តរជាតិ ដល់មន្ត្រី និងអ្នកស្ម័គ្រចិត្ត )
  - រាយការណ៍ ពីវត្តមាន និងអវត្តមានជូនអង្គប្រជុំ
  - ឯឧ. ហោ ប៊ុនឡេងៈ នៅក្នុងការប្រជុំនេះការសំខាន់គឺការអនុម័តផែនការយុទ្ធសាស្ត្រជាតិទី ៤ ដូចនេះមាន២ចំនុច ដែលគួរពិចារណាគឺៈ
    - រាយការណ៍ពីវឌ្ឍនភាពខ្លីបានហើយព្រោះរបាយការណ៍នេះគាត់តើអាចអានបាន
    - បទបង្ហាញផែនការយុទ្ធសាស្ត្រជាតិទី៤
    - ចំពោះសេវាសុខាភិបាលជារបាយការណ៍បច្ចេកទេសគួរតែក្រុមប្រឹក្សាបច្ចេកទេស (TAB) ចងក្រងជារួមមួយហើយសុំយកមកបង្ហាញនៅក្នុងការប្រជុំ PAB ។

ឯឧ.អគ្គលេខាធិការ ស្នើជូនឯឧ. ហោ ប៊ុនឡេង រៀបចំបទបង្ហាញរយៈពេល ៥នាទីអំពីវឌ្ឍនភាព។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង ១០:១០ នាទីព្រឹក ថ្ងៃ ខែ ឆ្នាំ ដដែល ប្រកបដោយបរិយាកាសរីករាយ និងស្និទ្ធស្នាល ជាទីបំផុត។

ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ២០១៥

ឯកភាពនិងគោរពជូនឯ.ឧ.អគ្គលេខា ពិនិត្យសំរេច

មន្ត្រីទទួលបន្ទុក

បានឃើញ និងឯកភាព អគ្គលេខាធិការ

អគ្គលេខាធិការរងនិង ជាប្រធាននាយកដ្ឋាន

ឱសថ. ចេង ថា

**វេជ្ជ. រស់ សីលវ៉ាត់**

**ឯកឧត្តមវេជ្ជ. តែង គន្នី**